ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
អគ្គនាយកដ្ឋានយោធសេវា
នាយកដ្ឋានព័ត៌មាន
លេខ: ៧១០/ន.៧
៤/២០១៥

# សេចក្តីប្រកាសជូនព័ត៌មាន

ក្រោមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងអង្គការសហប្រជាជាតិ ក្រសួងការពារជាតិនៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចបញ្ជូនកងអនុសេនាធំវិស្វកម្មសំណង់លេខ៥៤៩ ចំនួន២១៦ នាក់ ចូលរួមបេសកកម្មពហុវិស័យខ្នាតរួមគ្នា នៃសហប្រជាជាតិ ដើម្បីស្ថេរភាពនៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល ហៅកាត់ថា (MINUSCA) និងកងអនុសេនាធំវិស្វកម្មលេខ ៩៣៦ ចូលរួមបេសកកម្មអង្គការសហប្រជាជាតិ នៅប្រទេសលីបង់ ហៅកាត់ថា ( UNIFIL ) នៅថ្ងៃច័ន្ទ ទី០២ ខែវិច្ឆិកាឆ្នាំ២០១៥ ។

ពិធីជូនដំណើរជាផ្លូវការ នឹងប្រព្រឹត្តិទៅ ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ **ប្រាក់ សុខុន** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងជាប្រធានគណៈកម្មាធិការជាតិសម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងតំណាងអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ព្រមទាំងភ្ញៀវជាតិ និងអន្តរជាតិជាច្រើនចូលរួមនា **ថ្ងៃទី០២ ខែ វិច្ឆិកា វេលាម៉ោង ០៨:០០ ព្រឹក** នៅមូលដ្ឋានកងទ័ពអាកាសពោធិ៍ចិនតុង ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ តុលា ឆ្នាំ ២០១៥

នាយកដ្ឋានព័ត៌មាន